**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ២៥២. អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ទំហំ ៧១០០ ហិកតា ស្ថិតក្នុងឃុំរាម អូរឧកញ៉ាហេង ព្រៃនប់ ទួលទទឹង អណ្តូងថ្ម សំរោង នៃស្រុកព្រៃនប់ និងឃុំទំនប់រលក ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ សម្រាប់ធ្វើសម្បទានដីសង្គមកិច្ចជូនអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់ និតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីវិធាន និងនិតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់និតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី ០៧ ខែតុលា ឆ្នាំ ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញសេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាលកម្ពុជាលេខ ៨២សជណ.ចក ចុះថ្ងៃទី២៧ ខែតុលាឆ្នាំ២០០៩ ស្តីពី គោលនយោបាយផ្តល់សម្បទានដីសង្គមកិច្ចជូនអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ
-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.-**

ត្រូវបានកាត់ចេញពីផែនទីគម្របព្រៃឈើឆ្នាំ ២០០២ ទីតាំងដី ១ កន្លែងមានទំហំ ៧១០០ (ប្រាំពីរពាន់មួយរយ) ហិកតា នៅក្នុងឃុំរាម អូរឧកញ៉ាហេង ព្រៃនប់ ទួលទទឹង អណ្តូងថ្ម សំរុង នៃស្រុកព្រៃនប់ និងឃុំទំនប់រលក ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ដូចមានបង្ហាញក្នុងផែនទីជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ដោយកំណត់តាមចំណុចគោលដែលមាននិយាមកានៃប្រព័ន្ធកូអរដោនេ UTM Zone 48 N, Datum: WGS 1984 ដូចខាងក្រោម៖

| ចំណុច | X | Y | ចំណុច | X | Y | ចំណុច | X | Y |
|---|---|---|---|---|---|---|---|---|
| A | 355512 | 1173301 | J | 358369 | 1185173 | S | 359229 | 1172157 |
| B | 355512 | 1177920 | K | 362429 | 1182684 | T | 357803 | 1172296 |
| C | 356289 | 1178287 | L | 364268 | 1182780 | U | 355623 | 1173228 |
| D | 356308 | 1182292 | M | 364277 | 1178878 | V | 357348 | 1172819 |
| E | 357449 | 1183019 | N | 361529 | 1176936 | W | 357403 | 1172651 |
| F | 356644 | 1184162 | O | 362509 | 1173639 | X | 357175 | 1172651 |
| G | 357040 | 1184581 | P | 360314 | 1172246 | Y | 357106 | 1172506 |
| H | 357286 | 1184460 | Q | 360250 | 1172939 | Z | 357145 | 1172256 |
| I | 357599 | 1185006 | R | 359381 | 1172772 | | | |

**មាត្រា ២.-**

ត្រូវបានធ្វើអនុបយោគផ្ទៃដីទំហំចំនួន ៧១០០ (ប្រាំពីរពាន់មួយរយ) ហិកតា ដូចមានចែងក្នុងមាត្រា ១ ខាងលើនៃអនុក្រឹត្យនេះដែលជាដីក្នុងផែនទីគម្របព្រៃឈើឆ្នាំ ២០០២ មកជាដីឯកជនរបស់រដ្ឋ ។

**មាត្រា ៣.-**

ត្រូវបានប្រគល់អណត្តិកាន់កាប់ដីឯកជនរបស់រដ្ឋដូចមានក្នុងមាត្រា ២ ខាងលើនេះ ជូនអភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ ជាអាជ្ញាធរកាន់កាប់ដីរដ្ឋ ដើម្បីស្នើសុំចុះបញ្ជីជាដីឯកជនរបស់រដ្ឋ និងសម្រាប់ធ្វើសម្បទានដីសង្គមកិច្ចជូនអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់សមាជិក គសសជ
- អគ្គលេខាធិការដ្ឋាន គសសជ
- ដូចមាត្រា ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ចំនុចនិយាមការនៃប្រពន្ធ័កូអរដោនេ 48 N_ UTM, WGS 84 របស់ទីតាំងសម្បទានដីសង្គមកិច្ចទំហំ ៧.១០០ (ប្រាំពីរពាន់មួយរយ) ហិកតា

ស្ថិតនៅ ឃុំរាម អូរឧកញ៉ាហេង ព្រៃនប់ ទួលទទឹង អណ្តូងថ្ម សំរ៉ុង នៃស្រុកព្រៃនប់ និង ឃុំទំនប់រលក ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ

ឧបសម្ពន្ធ័អនុក្រឹត្យលេខ៖ [illegible] ចុះថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១១

| ចំណុច | X | Y |
|---|---|---|
| A | 355512 | 1173301 |
| B | 355512 | 1177920 |
| C | 356289 | 1178287 |
| D | 356308 | 1182292 |
| E | 357449 | 1183019 |
| F | 356644 | 1184162 |
| G | 357040 | 1184581 |
| H | 357286 | 1184460 |
| I | 357599 | 1185006 |
| J | 358369 | 1185173 |
| K | 362429 | 1182684 |
| L | 364268 | 1182780 |
| M | 364277 | 1178878 |
| N | 361529 | 1176936 |
| O | 362509 | 1173639 |
| P | 360314 | 1172246 |
| Q | 360250 | 1172939 |
| R | 359381 | 1172772 |
| S | 359229 | 1172157 |
| T | 357803 | 1172296 |
| U | 355623 | 1173228 |
| V | 357348 | 1172819 |
| W | 357403 | 1172651 |
| X | 357175 | 1172593 |
| Y | 357106 | 1172506 |
| Z | 357145 | 1172256 |

ផែនទីបង្ហាញទីតាំងសម្បទានដីសង្គមកិច្ចទំហំ ៧.១០០ (ប្រាំពីរពាន់មួយរយ) ហិកតា
ស្ថិតនៅ ឃុំពាម អូរឧកញ៉ាហេង ព្រៃនប់ ទួលទទឹង អណ្តូងថ្ម សំរុង នៃស្រុកព្រៃនប់ និង
ឃុំទំនប់រលក ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ
ឧបសម្ព័ន្ធអនុក្រឹត្យលេខ ២៥២ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០១១




COORDINATESYSTEM
Projection UTM
Zone 48N
Datum WGS84
Spheroid Everest

0 0.5 1 2
Kilometers

ទីតាំងសម្បទាន ដីសង្គមកិច្ច